01030107

E318

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13/10/2014
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**សាធារណៈ / Public**

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម យ៉ា សុខន ប្រធានស្តីទីនៃអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **សេចក្តីបញ្ជាក់បំភ្លឺអំពីផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសុំឱ្យស្តាប់ទឡ្ហីករណ៍ថែមទៀតទាក់ទងទៅនឹងសញ្ញាណដែលថា សំណុំរឿង ០០២/០១ គឺជាមូលដ្ឋានរួមនៃសំណុំរឿង ០០២/០២ ក្នុងគោលបំណងដើម្បីបញ្ជាក់បំភ្លឺអំពីផលវិបាកជាក់ស្តែង និងផលវិបាកផ្លូវច្បាប់ រួមទាំង ផលវិបាកលើភ័ស្តុតាង ដែលកើតចេញពីការបំបែកកិច្ចដំណើរការនីតិវិធីទាំងនេះ[1]។ អង្គជំនុំជម្រះកត់

---

[1] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ (សវនាការបឋមបន្ថែម) ទំព័រ ២៥-២៨, ៣០-៣១, ៣៣, ៤០ (ភាសាអង់គ្លេស)។ ការបង្ហាញពីបញ្ហាអង្គច្បាប់ដែលមេធាវីការពារក្តីលោក ខៀវ សំផន មានបំណងលើកឡើងនៅក្នុងសវនាការបឋមសម្រាប់សំណុំរឿង ០០២/០២ ឯកសារ E305/11 ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៨។

សម្គាល់ឃើញថា សំណើសុំនេះបានធ្វើឡើងនៅក្នុងអំឡុងពេលសវនាការបឋមបន្ថែម ដែលបានប្រព្រឹត្តទៅមួយថ្ងៃក្រោយពីអង្គជំនុំជម្រះតុលាការកំពូលបានជូនដំណឹងអំពីសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម ទៅកាន់ភាគី និងនៅមុនពេលដែលភាគីមានពេលវេលាដើម្បីស្វែងយល់អំពីសេចក្តីសម្រេចនេះឱ្យបានពេញលេញ[2]។

២. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្តីសម្រេចរបស់ អ.ជ.ត.ក បានបញ្ជាក់បំភ្លឺអំពីស្ថានភាពនៃបទចោទដែលនៅសេសសល់ និងផលវិបាកផ្នែកនីតិវិធីនៃការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀត ហើយបានសន្និដ្ឋានថា បញ្ហាចោទបែបនេះ "នឹងលែងធ្វើឱ្យប៉ះពាល់ដល់ការត្រៀមរៀបចំក្នុងការការពារខ្លួន" នៅក្នុងសំណុំរឿង ០០២/០២ ទៀតឡើយ[3]។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងពុំទទួលយកទឡ្ហីករណ៍បន្ថែមទៀតលើបញ្ហានេះនៅក្នុងពេលនេះឡើយ។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រសិនបើមានបញ្ហាចោទជាក់លាក់ និងជាក់ស្តែងណាមួយលេចឡើងនៅក្នុងអំឡុងពេលដំណើរការជំនុំជម្រះ បញ្ហាចោទទាំងនេះនឹងត្រូវយកមកពិភាក្សា និងសម្រេចតាមករណីជាក់ស្តែងនីមួយៗតែម្តង។

៣. យ៉ាងណាក៏ដោយ ដើម្បីជាប្រយោជន៍ដល់ភាគី អង្គជំនុំជម្រះមានបំណងបញ្ជាក់ឡើងវិញអំពីចំណុចសំខាន់ៗខាងក្រោមដែលត្រូវបានដកស្រង់ចេញមកពីសេចក្តីសម្រេចរបស់ អ.ជ.ត.ក និងសូមរម្លឹកដល់ភាគីអំពីគោលការណ៍ណែនាំពាក់ព័ន្ធ ដែលអង្គជំនុំជម្រះបានផ្តល់ជូន៖

ក/ សំណុំរឿងគឺនៅដដែលសម្រាប់ការជំនុំជម្រះនីមួយៗនៅក្នុងសំណុំរឿង ០០២[4]។

---

[2] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ (សវនាការបឋមបន្ថែម) ទំព័រ ២៣-២៤, ២៨ (ភាសាអង់គ្លេស), សូមមើល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ E301/9/1/1/3 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ (សេចក្តីសម្រេចរបស់ អ.ជ.ត.ក)។

[3] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៨៦។

[4] ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ (សវនាការបឋមបន្ថែម) ទំព័រ ២១ (ភាសាអង់គ្លេស)។ ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និងនីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E302/5 ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ៧។

ខ/ ភស្តុតាងដែលត្រូវបានទទួលយកដាក់បញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ នឹងត្រូវប្រើប្រាស់នៅក្នុងសំណុំរឿង ០០២/០២[5] ដែរ ដោយកំណត់ថា ភស្តុតាងដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬត្រូវបានពិនិត្យនៅក្នុងសំណុំរឿង ០០២/០១ រួចហើយ នឹងនៅតែត្រូវរក្សាទុកនៅក្នុងសំណុំរឿង ០០២/០២[6]។ ការកំណត់បែបនេះគឺសម្រាប់ទាំងភស្តុតាងពីសក្ខីកម្ម និងភស្តុតាងជាឯកសារ។

គ/ ហេតុដូច្នេះ មិនចាំបាច់ត្រូវមានការវាយតម្លៃសាជាថ្មីទៅលើការទទួលយកភស្តុតាងទាំងនោះឡើយ[7]។ លេខសម្គាល់ E3 ដែលត្រូវបានកំណត់សម្រាប់ភស្តុតាងនៅក្នុងដំណើរការនីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ នឹងនៅតែរក្សាដូច្នេះដដែលនៅក្នុងសំណុំរឿង ០០២/០២[8]។ ដូចគ្នាដែរ សក្ខីកម្មផ្សេងៗដែលត្រូវបានស្តាប់ក្នុងអំឡុងពេលនៃសំណុំរឿង ០០២/០១ នឹងនៅតែជាផ្នែកមួយនៃភស្តុតាងក្នុងសំណុំរឿង ០០២/០២ ដដែល។

---

5 សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៧៥, ៨៥។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1 ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ២៣។ ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និងនីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E302/5 ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ៧។

6 ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ (សវនាការបឋមបន្ថែម) ទំព័រ ២១ (ភាសាអង់គ្លេស)។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1 ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ២៣។ ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និងនីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E302/5 ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ៧។

7 សេចក្តីសម្រេច កថាខណ្ឌ ៧៥។

8 ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាង និងនីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ ឯកសារ E302/5 ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ៧។

ឃ/ យ៉ាងណាក៏ដោយ ហើយដើម្បីធានាឲ្យមានការពិភាក្សាដេញដោលឲ្យបានពេញលេញ ភាគីអាចលើកឡើងអំពីសំណួរផ្សេងៗ អំពីភាពពាក់ព័ន្ធ ហើយនឹងមានឱកាសដើម្បីពិនិត្យ និងតវ៉ាទៅលើភ័ស្តុតាងដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ រួចហើយនោះ ឲ្យតែភ័ស្តុតាងទាំងនេះទាក់ទងនឹងការចោទប្រកាន់ថ្មីៗនៅក្នុងសំណុំរឿង ០០២/០២[9]។

ង/ សេចក្តីសម្រេចផ្សេងៗដែលបានធ្វើនៅក្នុងសំណុំរឿង ០០២/០១ រួមទាំង សេចក្តីសម្រេចដែលបានផ្អែកទៅលើភ័ស្តុតាងដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ផងដែរនោះ មិនចងកាតព្វកិច្ចចំពោះអង្គជំនុំជម្រះទេ "ហើយធាតុផ្សំរួមនៃអង្គហេតុក្នុងសំណុំរឿងទាំងអស់ក្នុងសំណុំរឿង ០០២ នឹងត្រូវបង្ហាញសាជាថ្មី"[10]។

ច/ អង្គជំនុំជម្រះនឹងមិនបញ្ជូនការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌណាមួយពីសំណុំរឿង ០០២/០១ ទៅសំណុំរឿង ០០២/០២ ឡើយ[11]។

---

[9] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៧៥។

[10] *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៨៥។

[11] *សូមមើល* សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៨៥។